# ផ្តោតការយកចិត្តទុកដាក់លើការងារដែលសំខាន់សម្រាប់ស្ត្រី

## ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) បាននិងកំពុងផ្តោតការយកចិត្តទុកដាក់ជាពិសេសលើបញ្ហាទាំងឡាយដែលមានសារៈសំខាន់សម្រាប់ស្ត្រីនៅក្នុងវិស័យការងារទាំងអស់របស់ខ្លួន



Photo credit: OHCHR

សិក្ខាកាមចូលរួមសន្និសីទសម្រាប់ស្ត្រីនៅក្នុងប្រព័ន្ធតុលាការ សហការរៀបចំឡើងដោយការិយាល័យOHCHR សម្រាប់ជារូបភាព

លោកស្រី **បេ គឹមយ៉ាង** ដែលមកពីខេត្តស្ទឹងត្រែង ជាខេត្តដាច់ស្រយាលមួយ ពិតជាមិនដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលជាច្រើន ឬក៏យ៉ាងហោចណាស់ មិនបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលឲ្យបានច្រើនតាមដែលលោកស្រីចង់នោះទេ។ ហើយនៅពេលដែលលោកស្រីបានចូលរួម លោកស្រីហាក់ចាញ់ប្រាបគេ ដោយឃើញមានចំនួនសិក្ខាកាមជាបុរសច្រើនលើសលុបនៅក្នុងបន្ទប់ លោកស្រីយល់ថាមានការលំបាកក្នុងការនិយាយ និងចូលរួមឲ្យបានពេញលេញនៅក្នុងសិក្ខាសាលាទាំងនោះ។ ដោយហេតុនេះហើយ ទើបលោកស្រីមានសេចក្តីរីករាយជាខ្លាំងនៅពេលដែលលោកស្រីត្រូវបានអញ្ជើញចូលរួមក្នុងសន្និសីទមួយសម្រាប់ចៅក្រម និងព្រះរាជអាជ្ញាជាស្ត្រី ទូទាំងប្រទេសកម្ពុជា កាលពីខែវិច្ឆិកា ឆ្នាំ២០១៤ ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌ ក្រោមការឧបត្ថម្ភគាំទ្រពីការិយាល័យ OHCHR និងអង្គការសហប្រជាជាតិដើម្បីស្ត្រី (UN Women)។

សន្និសីទនេះមានការចូលរួមពីចៅក្រម និងព្រះរាជអាជ្ញាជាស្ត្រីចំនួន ៥០ រូប សិក្សាអំពីការអនុវត្តច្បាប់ឲ្យបានល្អប្រសើរ ដោយសង្កត់ធ្ងន់លើច្បាប់ជាតិ និងច្បាប់អន្តរជាតិដែលទាក់ទងនឹងអំពើហិង្សាផ្អែកលើយេនឌ័រនិងសមភាពយេនឌ័រ រួមទាំងអនុសញ្ញា អ.ស.ប ស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ។ ដោយសារចំនួនស្ត្រីដែលបម្រើការនៅក្នុងប្រព័ន្ធតុលាការកម្ពុជាមានកម្រិតទាបខ្លាំង គឺ ១៣% គិតត្រឹមខែកុម្ភៈ ឆ្នាំ ២០១៥ នេះបើយោងតាមស្ថិតិរបស់រាជរដ្ឋាភិបាល សន្និសីទនេះ បានអនុញ្ញាតផងដែរឲ្យសិក្ខាកាមជាស្ត្រី ផ្លាស់ប្តូរបទពិសោធន៍ និងគំនិតរបស់ខ្លួន អំពីរបៀបជម្រុញភាពជាតំណាងរបស់ស្ត្រីនៅក្នុងវិស័យយុត្តិធម៌។ ការពិភាក្សា និងការទំនាក់ទំនងធ្វើឡើងនៅក្នុងអំឡុងនៃកិច្ចប្រជុំនេះ បានធ្វើឲ្យសិក្ខាកាមអំពាវនាវឲ្យមានការបង្កើតបណ្តាញចៅក្រមស្ត្រី ហើយចៅក្រម និងព្រះរាជអាជ្ញាដែលមានវត្តមាន បានស្នើសុំឲ្យមានវគ្គបណ្តុះបណ្តាលបន្ត ដើម្បីពិភាក្សាអំពីរបៀបអនុវត្តគំនិតនេះតទៅទៀត។

> "ខ្ញុំមិនដែលបានចូលរួមក្នុងសន្និសីទបែបនេះទេពីមុនមក។ ដោយសារមានតែស្ត្រីនៅក្នុងបន្ទប់សិក្ខាសាលា ធ្វើឲ្យយើងទាំងអស់គ្នាមានឱកាសនិយាយស្តី និងចែករំលែកគំនិតអំពីរបៀបអនុវត្តច្បាប់នេះបានល្អប្រសើរ។"
>
> លោកស្រី បេ គឹមយ៉ាង
> ចៅក្រមសាលាដំបូងខេត្តស្ទឹងត្រែង